LOWELL COMMUNITY CHARTER PUBLIC SCHOOL

206 Jackson Street Lowell, MA 01852 Phone (978) 323-0800 Fax (978) 323-4600 www.lccps.org

ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៩

ជូនចំពោះ មាតាបិតាជាទីរាប់អាន,

សូមអរគុណចំពោះការយកចិត្តទុកដាក់សាលារៀនសាធារណៈសហគមន៍ឆាទ័រនៃទីក្រុងឡូវែល្ល(សាលារៀនឆាទ័រ LCCPS)។ សាលារៀនឆាទ័រគឺជាសាលារៀនរដ្ឋដែលកំពុងចុះឈ្មោះសិស្សរៀនក្នុងពេលនេះចាប់ពីថ្នាក់មត្តេយ្យបឋម១ K1 ដល់ថ្នាក់ទីប្រាំបី។ សាលារៀនឆាទ័របានត្រូវបង្កើតឡើងក្រោមច្បាប់ឆាទ័រ Commonwealth Charter ក្នុងឆ្នាំ២០០០។ សាលារៀនឆាទ័រស្វាគមន៍ទទួលកូនសិស្សក្នុងរដ្ឋម៉ាស្សាឈូសិត ទោះបីជាសិទ្ធិចូលរៀនត្រូវផ្តល់ឱ្យសិស្សក្នុងក្រុងឡូវែល្ល និងបងប្អូនបង្កើតសិស្សកំពុងរៀនក្តី។ សាលារៀនឆាទ័រមិនរើសអើងលើពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ជំនឿ ភេទ លក្ខណៈភេទ ជនជាតិភាគតិច ទំនោរផ្លូវភេទ ខ្សោយសមត្ថភាពផ្លូវចិត្ត ឬកាយ ស្ថានភាពគ្មានជំរក វ័យ ពូជពង្ស ហាត់កីឡា តម្រូវការ ពិសេស សមត្ថភាពជំនាញភាសាអង់គ្លេស ឬភាសាអន្តរជាតិ ឬសំរេចការសិក្សាមុនពេល។

សំរាប់ឆ្នាំសិក្សា ២០២០-២០២១ យើងកំពុងទទួលពាក្យសិស្សចូលរៀនចាប់ពីថ្នាក់មត្តេយ្យសិក្សាបឋម១ K1 ដល់ថ្នាក់ទី៨។ ថ្ងៃទទួលពាក្យសិស្សចូលរៀនត្រូវផុតកំណត់ **ថ្ងៃច័ន្ទ ទី២៤ ខែកុម្ភៈ ២០២០ ម៉ោង១២:០០ថ្ងៃត្រង់**។ ប្រសិនបើចំនួនពាក្យសិស្សចូលរៀនត្រូវទទួលបានច្រើនជាងកន្លែងទំនេរក្នុងថ្នាក់ ការចាប់ឆ្នោតនឹងត្រូវរៀបចំធ្វើតាមថ្នាក់នោះនៅ **ថ្ងៃពុធ ទី៤ ខែមិនា២០២០** ដើម្បីកំណត់សិស្សដែលត្រូវផ្តល់ឱ្យកន្លែងថ្នាក់រៀន។ សូមមើលគោលការណ៍ចុះឈ្មោះសិស្សចូលរៀនសំរាប់ព័ត៌មានលំអិតបន្ថែមទៀត។

**គោលការណ៍ដាក់ពាក្យសិស្សចូលរៀន**

1. បេក្ខភាពសិស្សត្រូវតែជាពលរដ្ឋនៃរដ្ឋម៉ាស្សាឈូសិត **ដើម្បីដាក់ពាក្យ ចុះឈ្មោះ និងចូលរៀន** នៅសាលារៀនឆាទ័រនៃរដ្ឋម៉ាស្សាឈូសិត។ បេក្ខភាពសិស្សត្រូវមានសំបុត្របញ្ជាក់ត្រឹមត្រូវចំនួនពីរ(២)ច្បាប់អំពីអាសយដ្ឋាន លើកលែងតែករណីស្ថានភាពសិស្សគ្មានទីជំរក ដែលត្រូវបានលើកលែងពីតម្រូវការទាំងនេះ។ (សូមមើលការចុះឈ្មោះចូលរៀនសំរាប់ការបំពេញឯកសារ)។
2. អាយុកំណត់ចូលរៀនសំរាប់**ថ្នាក់មត្តេយ្យបឋម១ (KI)** គឺអាយុបួនឆ្នាំគិតចាប់ពីថ្ងៃ**ទី១ខែកញ្ញា** សំរាប់ឆ្នាំចុះឈ្មោះចូលរៀន។
3. អាយុកំណត់ចូលរៀនសំរាប់**ថ្នាក់មត្តេយ្យបឋម២ (K2)** គឺអាយុប្រាំឆ្នាំ គិតចាប់ពីថ្ងៃ**ទី១ខែកញ្ញា** សំរាប់ឆ្នាំចុះឈ្មោះចូលរៀន។
4. សិទ្ធិចូលរៀនសំរាប់សិស្សមត្តេយ្យបឋម១ និង២ តម្រូវឱ្យមានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតត្រឹមត្រូវពីរដ្ឋាភិបាល ដូចជាលិខតឆ្លងដែនទំរង់ **I-94** ជាដើម។
5. បេក្ខភាពសិស្សចាប់ពីថ្នាក់ទីមួយដល់ទីប្រាំបី ត្រូវបំពេញបញ្ជាក់ការសិក្សាបញ្ចប់ថ្នាក់រៀនកន្លងមក មុនពេលដែលពួកគេមកស្វែងរកការទទួលឱ្យចូលរៀន។ បេក្ខភាពសិស្សមានសិទ្ធិចូលរៀនតម្រូវឱ្យមានរបាយការណ៍ការសិក្សា ឬឯកសារសិក្សាមកពីសាលារៀន ឬសាលារៀនមណ្ឌលដែលបញ្ចប់ពីការសិក្សាបញ្ចបកន្លងមក។ ឯកសារចាំបាច់តម្រូវឱ្យផ្ញើត្រឡប់មកសាលារៀនវិញនៅមុនថ្ងៃទី១៥ ខែសីហា។

មាតាបិតាត្រូវស្វែងយល់អំពីសាលារៀនឆាទ័រនៅមុនពេលមកដាក់ពាក្យសិស្សចូលរៀន។ សូមចូលមើលតាមវេបសាយរបស់សាលារៀនយើង និងគោលការណ៍ចុះឈ្មោះរៀនសំរាប់មួយថ្ងៃនៃថ្ងៃប្រកាសជូនដំណឹងរួមមាន **ថ្ងៃអង្គារទី៣ ធ្នូ ២០១៩, ថ្ងៃព្រហស្បតិ៍ទី១៦ មករា ២០២០ ម៉ោង៥:៣០ល្ងាច ឬថ្ងៃពុធទី៥ ខែកុម្ភៈ ២០២០ម៉ោង៩:០០ព្រឹក**។ យើងផ្តល់ជូនថ្ងៃបន្ថែមសំរាប់កំណត់ពេលអញ្ជើញមកទស្សនាសាលារៀនរៀងរាល់ថ្ងៃអង្គារចាប់ពីម៉ោង៩:៣០ដល់១០:០០ព្រឹក។ សូមទាក់ទងមកយើងខ្ញុំតាមទូរស័ព្ទលេខ 978-323-0800 ឬអ្នកស្រី Mary Don អ៊ីមែល mdon@lccps.org ដើម្បីកំណត់ពេលអញ្ជើញមកចាប់ផ្តើមពីថ្ងៃអង្គារទី១២ ខែវិច្ឆិកា ២០១៩។

**វិធីដាក់ពាក្យ:**

1. ត្រូវបំពេញពាក្យចូលរៀន(ពាក្យមួយសំរាប់សិស្សម្នាក់)។ ការដាក់ពាក្យតាមអនឡាញវេបសាយសាលារៀន www.lccps.org ឬ
2. ត្រូវប្រគល់ពាក្យដែលបានបំពេញត្រឹមត្រូវរួចហើយមកសាលារៀន (មើលអាសយដ្ឋានខាងក្រោម) ឬ
3. ត្រូវផ្ញើពាក្យដែលបានបំពេញត្រឹមត្រូវរួចមកតាមអ៊ីមែល jwangutsi@lccps.org ឬ
4. ត្រូវផ្ញើពាក្យដែលបានបំពេញត្រឹមត្រូវរួចមកតាមអាសយដ្ឋានខាងក្រោមនេះ

Lowell Community Charter Public School
Attn: Admission
206 Jackson Street
Lowell, MA 01852

Regards,
P. Deborah Motew
Director of Operations